**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជានៅភ្នំពេញថ្មី**
**ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៧**
*ខ្ញុំមិនមែនពន្លឺទេ ប៉ុន្តែខ្ញុំបង្ហាញពន្លឺ*

អត្ថបទទី១៖ អស ៦១,១-២ក.១០-១១
អត្ថបទទី២៖ ១ថស ៥,១៦-២៤
ដំណឹងល្អ៖ យហ ១,៦-៨.១៩-២៨

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងមានអំណរសប្បាយដោយបានស្តូត "**ខ្ញុំមានចិត្តអំណរសប្បាយអរពន់ពេកណាស់**" ក្នុងអត្ថបទទីពីរ "**ចូរមានអំណរសប្បាយជានិច្ច ចូរអធិដ្ឋានជាដរាប ចូរអរព្រះគុណព្រះជាម្ចាស់ គ្រប់កាលៈទេសៈទាំងអស់**"។ នៅថ្ងៃអាទិត្យទីបីនៃរដូវរង់ចាំ ព្រះសហគមន៍ណែនាំឲ្យយើងទាំងអស់គ្នា ចូលនៅក្នុងអំណរសប្បាយមួយយ៉ាងពិសេស គឺអំណរសប្បាយដែលព្រះនាងម៉ារីដែលជិតណែនាំឲ្យព្រះយេស៊ូប្រសូត។ អំណរសប្បាយ ដែលលោកយ៉ូហានបាទីស្តកំពុងធ្វើពិធីជ្រមុជទឹក ដើម្បីឲ្យប្រជាជនកែប្រែចិត្តគំនិត និងជាពិសេសទទួលស្វាគមន៍ព្រះយេស៊ូ យើងចូលនៅក្នុងអំណរសប្បាយនៃព្រះសហគមន៍ទាំងមូល។ ប្រសិនបើយើងបើកភ្នែក ពីមួយថ្ងៃទៅមួយថ្ងៃ រាល់ពេលព្រះសហគមន៍ជួបជុំគ្នាម្តងៗ ពោរពេញដោយអំណរសប្បាយ។

កន្លងមកគ្រីស្តបរិស័ទយើង១២៦នាក់ ដែលបានធ្វើដំណើរទៅប្រទេសភូមា ដើម្បីជួបជាមួយសម្តេចប៉ាប។ នេះជាអំណរសប្បាយមួយយ៉ាងពិសេស នៅពេលយើងជួបជុំគ្នាជាមួយគ្រីស្តបរិស័ទនៅប្រទេសភូមា។ ពេលយើងជួបជុំគ្នាជាមួយសម្តេចប៉ាប ដែលមកសួរសុខទុក្ខផ្ទាល់ ដល់គ្រីស្តបរិស័ទនៅក្នុងទ្វីបអាស៊ីយើង នេះជាអំណរសប្បាយមួយយ៉ាងពិសេស។ អភិបូជា ចុងក្រោយដែលយើងមានជាមួយសម្តេចប៉ាប នៅពេលយើងនៅវិសាលវិហារនៅប្រទេសភូមា សម្តេចប៉ាបជួបជាមួយយុវជនទាំងអស់ និងពាក្យចុងក្រោយនៃធម្មទេសនារបស់សម្តេចប៉ាប ដែលនិយាយទៅកាន់យុវជនថា "**យុវជនអើយ! សូមការពារថែរក្សាអំណរសប្បាយជានិច្ច**"។

ម្សិលមិញខ្ញុំទៅប្រទេសឡាវ ដើម្បីគោរពមរណៈសាក្សីឡាវគម្រប់មួយឆ្នាំ ព្រះសហគមន៍នៅឡាវ មានអំណរសប្បាយខ្លាំងណាស់ ដោយសារទទួលស្វាគមន៍លោកកាឌីណា

ល់ថ្មី (លោកអភិបាលលីង) ដែលណែនាំឲ្យព្រះសហគមន៍មានសេរីភាពច្រើនជាងមុន។ នៅឆ្នាំមុន ពេលយើងថ្វាយអភិបូជាគោរពមរណៈសាក្សី យើងឃើញតំណាងរបស់រដ្ឋាភិបាលបានចូលរួមដែរ។ ម្សិលមិញ មានប្រធាននៃធម្មការ និងសាសនា បានចូលរួមដែរ ហើយនេះជាសញ្ញាសម្គាល់មួយយ៉ាងពិសេស សម្រាប់ព្រះសហគមន៍មួយដែលប៉ុន្មានឆ្នាំបានរស់នៅដោយគ្មានសេរីភាព គ្មានសិទ្ធិសេរីថ្វាយបង្គំ។ ប៉ុន្តែឥលូវយើងឃើញអំណរសប្បាយមួយនៃព្រះសហគមន៍នៅទីនោះ ជាសញ្ញាមួយដែលណែនាំឲ្យយើងត្រេកអររួមជាមួយគ្នា។

ប៉ុន្មានថ្ងៃកន្លងមក ខ្ញុំដើរតាមកន្លែងនីមួយៗ ទៅមន្ទីរឃុំឃាំងខេត្តកំពត ផ្ទះបងស្រីមេត្តាករុណា ផ្ទះបងប្រុសមេត្តាករុណា នៅឡាវ៉ាឡូ...។ យើងឃើញព្រះសហគមន៍ណែនាំឲ្យអ្នកជាប់នៅមន្ទីរឃុំឃាំង ដូចយើងស្តាប់ថ្ងៃនេះក្នុងគម្ពីរ "**ព្រះវិញ្ញាណរបស់ព្រះម្ចាស់សណ្ឋិតលើខ្ញុំ ដ្បិតព្រះអម្ចាស់បានចាក់ប្រេងអភិសេក ជួយថៃទាំអ្នកដែលបាក់ទឹកចិត្ត ប្រកាសប្រាប់ជនជាប់ជាឈ្លើយថាពួកគេនឹងរួចខ្លួន**"។ យើងជួបជាមួយអ្នកទោស៧០០នាក់ ប៉ុន្តែគេមានអំណរសប្បាយដោយសារឃើញទាំងលោកសង្ឃ ទាំងឥស្លាម ទាំងសាសនាយើងទៅអធិដ្ឋាន ដើម្បីបង្ហាញភាពកក់ក្តៅ។ ពេលយើងឃើញ រាប់រយគ្រួសារដែលទទួលការស្វាគមន៍យ៉ាងរាក់ទាក់ ពីបងស្រី ពីបងប្រុស យើងឃើញអំណរសប្បាយដែលយើងកំពុងចែករំលែកនៅក្នុងឱកាសបុណ្យណូអែល។

ប្រសិនបើយើងបើកភ្នែកពិចារណា ទោះបីយើងមានភ្លើង ទោះបីយើងមានបុណ្យព្រះយេស៊ូប្រសូតគ្រប់ទីកន្លែង សព្វថ្ងៃយើងដូចលោកយ៉ូហានបាទីស្ត ដែលទៅប្រកាសនៅកន្លែងនៅវាលរហោស្ថាន។ លោកយ៉ូហានមានប្រសាសន៍ថា "ខ្ញុំ**ជាសំឡេងបុរសម្នាក់ដែលស្រែកនៅវាលរហោស្ថាន**"។ វាលរហោស្ថាន ជាកន្លែងមួយដែលអត់មានអីសោះ មានតែដីខ្សាច់ មានតែសត្វពស់ មានសត្វផ្សេងៗ គ្មានទឹក គ្មានមនុស្ស។ លោកយ៉ូហានបាទីស្តទកវាលរហោស្ថានដើម្បីនិយាយ "**ចូរតម្រង់ផ្លូវថ្វាយព្រះអម្ចាស់**" ហេតុអ្វីលោកយ៉ូហានបាទីស្តរើសកន្លែងមួយដែលអត់មានមនុស្ស ដើម្បីប្រកាសអំពីដំណឹងល្អ? សព្វថ្ងៃទោះបីជាទីក្រុងរបស់យើងពោរពេញដោយ "Merry Christmas and Happy New Year" មានដើមសាប៉ុងគ្រប់ទីកន្លែង មានតាណូអែលធំទៅៗ ខ្ញុំឃើញនៅប្រទេសភូមាក៏មាន នៅប្រទេសឡាវក៏មាន ខ្ញុំឃើញនៅប្រទេសថៃក៏មាន ទាំងអស់គេគេកំពុងសរសើរបុណ្យណូអែល ប៉ុន្តែគេមិនដឹងជាអី? ដោយសារទោះបីយើងពោរពេញដោយសកម្មភាពនានា តាមពិតយើងអាច

និយាយថា សង្គមរបស់យើងសព្វថ្ងៃហាក់បីដូចជាវាលរហោស្ថានដែរ។ វាលរហោស្ថានដែលខ្វះអត្ថន័យ ដើម្បីណែនាំជីវិតរបស់យើង ដែលខ្វះផ្លូវ ដើម្បីរកឃើញពន្លឺនៅក្នុងជីវិតរបស់យើង។

លោកយ៉ូហានបាទីស្ដបាននិយាយ "**ខ្ញុំមិនមែនពន្លឺទេ ប៉ុន្តែខ្ញុំបង្ហាញពន្លឺ**"។ កុំឲ្យយើងវង្វេងភ្នែក ពន្លឺដែលយើងមើលឃើញស្អាតៗនៅគ្រប់ទីកន្លែង មិនមែនជាពន្លឺដើម្បីណែនាំឲ្យបំភ្លឺជីវិត ដើម្បីណែនាំឲ្យជីវិតរបស់យើងមានគោលដៅយ៉ាងច្បាស់។ សម្រាប់យើងជាគ្រីស្តបរិស័ទ យើងហាក់បីដូចជាលោកយ៉ូហានបាទីស្ដ នៅក្នុងវាលរហោស្ថាននៃសង្គមរបស់យើងសព្វថ្ងៃ។ សង្គមរបស់យើងសព្វថ្ងៃអភិវឌ្ឍខ្លាំងណាស់ តែសំខាន់កុំឲ្យអភិវឌ្ឍដើម្បីឲ្យតែល្អមើល តែសូមអភិវឌ្ឍចិត្តគំនិតមនុស្ស អភិវឌ្ឍផ្នែកយុត្តិធម៌ ដូចយើងស្ដាប់ថ្ងៃនេះ "**ខ្ញុំមានអំណរសប្បាយយ៉ាងខ្លាំងព្រោះតែព្រះអម្ចាស់ ខ្ញុំរីករាយយ៉ាងអស់ពីចិត្តព្រោះតែព្រះរបស់ខ្ញុំ ដ្បិតព្រះអង្គបានសង្គ្រោះខ្ញុំ**"។ ព្រះអង្គ បានយកសេចក្តីសុចរិតមកពាក់ឲ្យខ្ញុំ ដើម្បីឲ្យខ្ញុំទៅជាសញ្ញាសម្គាល់នៃយុត្តិធម៌ ដើម្បីឲ្យខ្ញុំទៅជាសញ្ញាសម្គាល់នៃ តម្លៃនៃជីវិត ដើម្បីឲ្យខ្ញុំទៅជាសញ្ញាសម្គាល់នៃអត្ថន័យនៃជីវិតថែមទៀត។

អំណរសប្បាយដែលខ្ញុំកំពុងនិយាយថ្ងៃនេះ មិនមែនអំណរសប្បាយដែលណែនាំឲ្យយើងជប់លៀងដោយអត់ដឹងមូលហេតុ អំណរសប្បាយដែលថ្ងៃនេះខ្ញុំទទួល ជាអំណរសប្បាយតែមួយគត់ "**ព្រះយេស៊ូកំពុងយាងមក**"។ យើងត្រូវការគិតពិចារណា យើងជាយុវជន យុវនារី យើងជាគ្រីស្តបរិស័ទ យើងជាឪពុកម្ដាយ យើងជាកូនក្មេងដែលទទួលពិធីជ្រមុជទឹកថ្ងៃនេះ **យើងធ្វើយ៉ាងម៉េច ដើម្បីទៅជាសាក្សីនៃអំណរសប្បាយមួយពិសេសដែលយើងទទួលនៅថ្ងៃនេះ?** យើងធ្វើយ៉ាងម៉េចដើម្បីណែនាំ ឲ្យព្រះសហគមន៍របស់យើងទៅជាសញ្ញាសម្គាល់នាពេលបច្ចុប្បន្ននេះទាំងនៅភ្នំពេញផង ទាំងនៅតាមភូមិនានាផង។

កុំឲ្យយើងភ្លេច អត្ថន័យនៃជីវិតរបស់យើងដែលរកឃើញនៅពេលយើងមើលព្រះយេស៊ូជាពន្លឺ និងយើងជាយ៉ូហានបាទីស្ដ យើងមិនមែនពន្លឺ យើងមិនមែនព្រះសង្គ្រោះ យើងមិនមែនព្រះយេស៊ូ ប៉ុន្តែយើងបង្ហាញឲ្យគេមើលឃើញព្រះយេស៊ូ យើងបង្ហាញឲ្យគេមើលឃើញពន្លឺ។ ដូចហោរាចារ្យគេដើរបានដោយសារគេមើលផ្កាយ និងផ្កាយនេះជាសញ្ញាសម្គាល់នៃពន្លឺរបស់ព្រះគ្រីស្ដផ្ទាល់។

ដូច្នេះនៅក្នុងបុណ្យព្រះយេស៊ូប្រសូតនេះ ឲ្យយើងទទួលអំណរសប្បាយពេញខ្លួន ដើម្បីឲ្យឆ្នាំខាងមុខ យើងអាចប្រកាសដំណឹងល្អតាមរយៈជីវិតរបស់យើង "**ខ្ញុំឲ្យនាំដំណឹងល្អទៅប្រាប់ដល់អ្នកដែលត្រូវគេជិះជាន់ ជួយថែទាំដល់អ្នកដែលបាក់ទឹកចិត្ត ប្រកាសប្រាប់ជនជាប់ជាឈ្លើយថាគេនឹងរួចខ្លួនហើយ ប្រកាសប្រាប់អ្នកជាប់ឃុំឃាំងថាពួកគេនឹងមានសេរីភាព ព្រមទាំងប្រកាសពីឆ្នាំដែលព្រះអម្ចាស់សម្តែងព្រះហឫទ័យមេត្តាករុណា**"។

ឲ្យយើងពិចារណា នៅក្នុងបុណ្យព្រះយេស៊ូប្រសូត យើងទទួលអំណរសប្បាយពេញខ្លួន ប៉ុន្តែយើងជាយ៉ូហានបាទីស្តនៅក្នុងវាលរហោស្ថាននៃសង្គមរបស់យើងសព្វថ្ងៃ ដើម្បីឲ្យព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺមនុស្សទាំងអស់។ នៅក្នុងអត្ថបទទីពីរ "**កុំរារាំងសកម្មភាពព្រះវិញ្ញាណដ៏វិសុទ្ធឡើយ**" សូមប្រយត្ន កុំឲ្យយើងទៅជាឧបសគ្គ ផ្ទុយទៅវិញឲ្យយើងទៅជាឧបករណ៍ ដើម្បីណែនាំឲ្យការសង្គ្រោះទៅគ្រប់ទីកន្លែង នៅក្នុងវាលរហោស្ថាននៃសង្គមរបស់យើង។ អាម៉ែន៕